THE UNIVERSITY OF AUCKLAND Te Whare Wānanga o Tāmaki Makaurau NEW ZEALAND | THE UNIVERSITY OF WESTERN AUSTRALIA | THE UNIVERSITY OF SYDNEY | USP THE UNIVERSITY OF THE SOUTH PACIFIC | Royal University of Phnom Penh

# ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងដំណើរការនៃការស្តារឡើងវិញបន្ទាប់ពីរងគ្រោះមហន្តរាយ៖ សហគមន៍រងផលប៉ះពាល់ពីគ្រោះមហន្តរាយនៅកម្ពុជា៖ សេចក្តីសង្ខេបសម្រាប់គោលនយោបាយ ៥

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើអាជីវកម្មខ្នាតតូច នៅក្រុងក្រចេះ ខេត្តក្រចេះ ប្រទេសកម្ពុជា

សេចក្តីសង្ខេបសម្រាប់គោលនយោបាយនេះ បង្ហាញពីការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ដល់អាជីវកម្មខ្នាតដូចយ៉ាងដូចម្តេចខ្លះ ក្នុងក្រុងក្រចេះ ខេត្តក្រចេះ ប្រទេសកម្ពុជា និងរបៀបដែលពួកគេបានឆ្លើយតបទៅនឹងផលប៉ះពាល់ទាំងនោះ។ វាថែមទាំងពិនិត្យលើស្ថាប័នគាំទ្រ និងអន្តរាគមន៍ ដែលអាចត្រូវបានពង្រឹង ដើម្បីកាត់បន្ថយផលប៉ះពាល់ និងបង្កើតអាជីវកម្មធន់នឹងអាកាសធាតុ។ ការសិក្សានេះគឺផ្អែកលើបទសម្ភាសន៍ជាមួយអាជីវកម្មខ្នាតតូចៗចំនួន៣២ រួមទាំងអ្នកលក់តាមផ្លូវ ហាងគ្រឿងទេស ភោជនីយដ្ឋាន និងផ្ទះសំណាក់។

## សារជាគន្លឹះ

---

- ការបង្កើតអាជីវកម្មខ្នាតតូចធន់នឹងអាកាសធាតុគឺសំខាន់ណាស់ ដោយសារសេដ្ឋកិច្ចរបស់ខេត្តក្រចេះពឹងផ្អែកយ៉ាងខ្លាំងទៅលើទំនាក់ទំនងរវាងកសិកម្ម និងទេសចរណ៍ និងសហគ្រាសដែលពាក់ព័ន្ធ។
- អាជីវកម្មត្រូវបានរងផលប៉ះពាល់ដោយមហន្តរាយដែលបណ្តាលមកពីអាកាសធាតុ រួមទាំងទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត។ ការប្រឈមអាជីវកម្ម និងទីតាំងផ្សេងៗ ការយល់ឃើញពីហានិភ័យអាកាសធាតុ និងចង្វាក់ផ្គត់ផ្គង់អាជីវកម្ម និងមូលដ្ឋានអតិថិជន បានឆ្លុះបញ្ចាំងពីកំរិតខុសគ្នានៃផលប៉ះពាល់ និងការឆ្លើយតបផ្សេងៗ។
- អាជីវកម្មបានទទួលយកយុទ្ធសាស្ត្របន្សាំមួយចំនួន ដូចជា ចល័តភាព ស្តុកទុកដាក់ ការរក្សាទុកធនធាន ការសន្សំហិរញ្ញវត្ថុ និងបំលាស់ទីតាំង។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្ត្រទាំងនេះគឺវិធានការបណ្តោះអាសន្ន និងផ្អែកលើគ្រោះមហន្តរាយ ជាជាងវិធានការរយៈពេលវែងជាប្រព័ន្ធ។
- ប្រព័ន្ធ និងបណ្តាលទ្រទ្រង់គឺមានដែនកំណត់។ អាជីវកម្ម ខ្វះជំនួយពីខាងក្រៅដែលត្រូវការ ពីដៃគូអាជីវកម្ម សហគ្រាស និងអាជ្ញាធរពាក់ព័ន្ធ។
- ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ដែលបន្សាំ បានទាំងរូបវន្ត និងព័ត៌មាន នឹងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពអាជីវកម្ម ដើម្បីរៀបចំសម្រាប់ និងដោះស្រាយជាមួយមុខសញ្ញាគញគ្រោះមហន្តរាយធម្មជាតិ។

Funded by APN ASIA-PACIFIC NETWORK FOR GLOBAL CHANGE RESEARCH

ដោយឡែក វាអាចរួមបញ្ចូល ការធ្វើឱ្យប្រសើរនូវហេដ្ឋារចនាសម្ព័ន្ធបន្ធូបន្ថយទឹកជំនន់ និងបង្កើនភាពងាយស្រួល និងទាន់ពេលវេលា នៃព័ត៌មានអាកាសធាតុ។

## បរិបទ

សេដ្ឋកិច្ចរបស់ខេត្តក្រចេះពឹងផ្អែកយ៉ាងខ្លាំងទៅលើកសិកម្ម ប៉ុន្តែទេសចរណ៍ ក៏កំពុងក្លាយជាវិស័យយ៉ាងសំខាន់បំផុតផងដែរ។ ច្រើនជាង ៨០%នៃប្រជាជនខេត្តគឺជាកសិករ។ ទោះជាយ៉ាងណាចំនួននៃសហគ្រាស ដែលទាក់ទងនឹងកសិកម្ម និងទេសចរណ៍ គឺកំពុងកើនឡើងជាបណ្តើរៗ។ យោងតាមជំរឿនសេដ្ឋកិច្ចឆ្នាំ ២០១១ មានចំនួន ១១.០៤៦ អាជីវកម្ម នៅក្នុងខេត្ត ស្មើប្រមាណចំនួន ២,២% នៃអាជីវកម្មសរុបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជីវកម្មស្ទើរតែទាំងអស់ គឺជាអាជីវកម្មខ្នាតតូច។

ខេត្តក្រចេះ ដែលមានទីតាំងតាមដងទន្លេមេគង្គមាន ប្រវត្តិរងផលប៉ះពាល់ ដោយមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិផ្សេងៗយូរលុងមកហើយ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ និងរន្ទះ។ ទឹកជំនន់ និងគ្រោះរាំងស្ងួតគឺ បានកើតឡើងញឹកញាប់ និងបំផ្លិចបំផ្លាញ បណ្តាលឱ្យហិនហោចសង្គម និងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ បន្ថែមពីនេះ ថ្មីៗនេះខេត្តបានទទួលរងនូវភ្លៀងខ្លាំង និងកើនឡើងរលកកំដៅ ដោយសារការប្រែប្រួលអាកាសធាតុ។

ការសិក្សាលើការប្រែប្រួលអាកាសធាតុក្នុងខេត្តក្រចេះបាន ផ្តោតយ៉ាងសំខាន់លើផលប៉ះពាល់លើកសិកម្ម។ យ៉ាងណាក៏ដោយ ដោយសារវត្តមាននៃការកើនឡើងរបស់សហគ្រាសធន់តូច និងការបង្កើនទំនាក់ទំនងរវាងកសិកម្ម និងទេសចរណ៍ នៅក្នុងសេដ្ឋកិច្ចខេត្ត វាគឺចាំបាច់ណាស់សម្រាប់ការយល់ដឹង ពីការប្រែប្រួលអាកាសធាតុ បានប៉ះពាល់ទៅលើអាជីវកម្មខ្នាតតូចដោយវិធីណា និងអ្វីដែលអាចធ្វើបានដើម្បីបង្កើតភាពធន់នឹងអាកាសធាតុ។

## ទឹកជំនន់ និងខ្យល់ព្យុះគឺជាមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិចំបងៗ ដែលប៉ះពាល់ទៅជីវកម្មខ្នាតតូច

អាជីវករច្រើនបាន រៀបរាបថា អាជីវកម្មរបស់ពួកគេ ត្រូវបានរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយធម្មជាតិផ្សេងៗ ដូចជាទឹកជំនន់ ខ្យល់ព្យុះ គ្រោះរាំងស្ងួត និងរន្ទះ។ យ៉ាងណាក៏ដោយ អាជីវកម្មបានជួបប្រទះនូវកំរិតខុសៗគ្នានៃភាពញឹកញាប់នៃការកើតមានគ្រោះមហន្តរាយ និងភាពខ្លាំងក្លាដោយអាស្រ័យលើការប្រឈមនឹងភាពរង់គ្រោះ និងទីតាំងរបស់ពួកគេ ការយល់ដឹងពីហានិភ័យប្រែប្រួលអាកាសធាតុ និងចង្វាក់ផ្គត់ផ្គង់អាជីវកម្មរបស់ពួកគេ និងមូលដ្ឋានអតិថិជន។

ជាឧទាហរណ៍ ទឹកជំនន់បានប៉ះពាល់ដល់អាជីវកម្មរបៀបមួយចំនួន។ ទាំងនេះបានរួមបញ្ចូលទាំងការថយចុះចំនួននៃអតិថិជន (ពិសេសអាជីវកម្ម ដែលទាក់ទងនឹងទេសចរណ៍) កាត់ផ្តាច់ផលិតផលផ្គត់ផ្គង់ផលិតផល (ជាពិសេសសម្រាប់អាជីវកម្ម ដែលពឹងផ្អែកលើលផលិតផលកសិកម្ម និងធនធានធម្មជាតិ) ហើយចុងក្រោយខាតបង់ប្រាក់ចំណេញ។ ចំពោះអាជីវកម្មដែលនៅតាមផ្លូវ (ជាពិសេសសម្រាប់អាជីវកម្មនៅតាមផ្លូវ ដូចជានៅជងផ្លូវធំៗ) ឬតំបន់លិចទឹកជាប្រចាំ (ដូចជាផ្សារកណ្តាល) ផលប៉ះពាល់ដូចជាបំផ្លិចបំផ្លាញផលិតផល សេវាកម្ម និងហាង បណ្តាលឲ្យមានការផ្លាស់ទីតាំងអាជីវកម្មទៅតំបន់គ្មានទឹកជំនន់។ ទឹកជំនន់ ក៏បានបង្អាក់ដល់ផែនការអាជីវកម្ម ឱកាស និងជំរើសមានដែនកំណត់ និងរារាំងសមត្ថភាពក្នុងការរីកលូតលាស់។ បន្ថែមលើការខាតបង់សេដ្ឋកិច្ច អាជីវការបានរាយការណ៍ថា ទឹកជំនន់ជាមូលហេតុប៉ះពាល់ដល់សុខភាពផ្លូវចិត្ត ទោះបីជាវាជាព្រឹត្តិការធម្មជាតិតាម រដូវកាលក៏ដោយ។

ខ្យល់ព្យុះត្រូវបានគេរាយការណ៍ថា ជាគ្រោះមហន្តរាយទី២ បន្ទាប់ពីទឹកជំនន់។ ដូចគ្នាដែរ ផលប៉ះពាល់របស់វាបានផ្លាស់ប្តូរ ដោយផ្អែកលើប្រភេទនៃអាជីវកម្ម ការប្រឈមនឹងភាពរងគ្រោះ និងទីតាំងនៃអាជីវកម្ម និងភាពងាយរងគ្រោះនៃសមាសភាពអាជីវកម្មផ្សេងៗ។ ផលប៉ះពាល់ ដែលបានកើតឡើងដោយសារខ្យល់ព្យុះ មានដូចជា បំផ្លាញហាង និងរបស់របរ ការបង្អាក់នៃផលិតផល និងសេវាកម្ម បាត់បង់ប្រាក់ចំណេញ និងការរំខានផ្លូវចិត្ត។

## ការឆ្លើយតបរបស់អាជីវកម្មចំពោះមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិគឺ ជាការឆ្លើយតបបណ្តោះអាសន្ន និងមានរយៈពេលខ្លី

អាជីវករបានរាយការណ៍ថា ពួកគេមិនធ្លាប់មានលទ្ធភាព ទទួលបានប្រព័ន្ធប្រកាសអាសន្នជាមុន ឬការផ្តល់ព័ត៌មានតាមប្រព័ន្ធបច្ចេកវិទ្យាណាមួយទេ។ ដូច្នេះ ពួកគេជឿលើប្រភពព័ត៌មានខុសៗគ្នា អំពីអាកាសធាតុ ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ។ ប្រភពទាំងនេះបានរួមមានការផ្សព្វផ្សាយបែបបុរាណ (ពិសេសវិទ្យុ និងទូរទស្សន៍) បណ្តាញផ្សព្វផ្សាយសង្គម (ជាពិសេសFacebook) អាជ្ញាធរមូលដ្ឋាន (តាមរយៈការប្រកាសផ្ទាល់មាត់) អ្នកជិតខាង និងអតិថិជន (តាមការនិយាយគ្នាផ្ទាល់) និងការសង្កេតផ្ទាល់ខ្លួន (ផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួន និងចំណេះដឹង)។

អាជីវកម្មនីមួយៗបានឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ តាមរបៀបផ្សេងៗ ដូចជា ការមិនធ្វើសកម្មភាពអ្វីទាំងអស់ ការបិទហាងជាបណ្តោះអាសន្ន ដោះស្រាយបញ្ហាជាបណ្តោះអាសន្ន (ដូចជាការជួលម៉ាស៊ីន បូមទឹកជំនន់ចេញពីហាង ឬជញ្ជូនគ្រឿងសង្ហារឹមក្នុងហាងទៅកាន់ទីខ្ពស់) និងការផ្លាស់ប្តូរទៅទីកន្លែងផ្សេងៗ (សម្រាប់អាជីវកម្មអាចចល័តបាន)។ យុទ្ធសាស្រ្តបន្សាំផ្សេងៗទៀត មានដូចជាស្តុកការរក្សាធនធាន ការសន្សំហិរញ្ញវត្ថុ និងការផ្លាស់ទីតាំង។ ទោះជាយ៉ាងណាក៏ដោយ យុទ្ធសាស្រ្តទាំងនេះគឺ

ជាយុទ្ធសាស្ត្របណ្តោះអាសន្ន និងផ្អែកលើលើគ្រោះមហន្តរាយ មិនមែនជាវិធានការបន្សាំជាប្រព័ន្ធសម្រាប់រយៈពេលវែងទេ។ សូម្បីតែអាជីវកម្មខ្នាត់ធំ ដូចជាក្រុមហ៊ុនទេសចរណ៍ ក៏មិនមានបញ្ចូល ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅក្នុងផែនការអាជីវកម្មរបស់ខ្លួនឡើយ ។

ទោះបីជាអាជីវករ បានគិតថា ខេត្តក្រចេះអាចជួបប្រទះនឹងមុខសញ្ញាគ្រោះមហន្តរាយធម្មជាតិដែលកើតឡើងជាញឹកញាប់ និងធ្ងន់ធ្ងរក៏ដោយ ក៏អាជីវករភាគច្រើន បានបង្ហាញពីការយល់ដឹងតិចតួចពីហានិភ័យអាកាសធាតុទៅលើអាជីវកម្មរបស់ពួកគេ ដូច្នេះហើយ ការត្រៀមលក្ខណៈទុកជាមុនមានកំរិតទាប។ មានបីប្រភេទនៃការយល់ដឹងពីហានិភ័យអាកាសធាតុក្នុងចំណោមអាជីវករទាំងអស់នោះ។ មួយគឺពួកគេមិនបានដឹងពីការប្រែប្រួលអាកាសធាតុ ថាជាហានិភ័យចំពោះអាជីវកម្មរបស់ពួកគេទាល់តែសោះ។ ដូច្នេះ ពួកគេមិនបានធ្វើផែនការសកម្មភាពទុកសម្រាប់បង្ការ ហើយក៏មិនមានឆន្ទៈ ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលបង្កើនការយល់ដឹងឡើយ។ ប្រភេទទីពីរគឺ អ្នកដែលឃើញខ្លី ពីប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើអាជីវកម្មរបស់ពួកគេ និងបានផ្អែកលើបទពិសោធន៍របស់ពួកគេ ពួកគេបានយល់បានដឹងពីផលប៉ះពាល់គ្រាន់មួយរយៈពេល និងការប៉ះពាល់តែទ្រព្យសម្បត្តិរូបវន្តតែប៉ុណ្ណោះ។ តាមរយៈការយល់ឃើញបែបនេះ ពួកគេបានប្រើយុទ្ធសាស្ត្ររយៈពេលខ្លីមួយ គឺគ្រាន់តែដើម្បីគេចវេសពីផលប៉ះពាល់ជាបណ្តោះអាសន្ន ដោយគ្មានគិតគូរកវិធានការសម្រាប់រយៈពេលវែងណាមួយឡើយ។ ប្រភេទទីបី និងមិនសូវមានគឺ អ្នកទាំងឡាយដែលបានយល់ដឹងពីហានិភ័យអាកាសធាតុមាន សភាពខ្លាំងក្លា និងធ្ងន់ធ្ងរពីព្រោះអាជីវកម្មរបស់ពួកគេ ធ្លាប់ប៉ះពាល់ដោយផ្ទាល់ ហើយខ្លាំក្លា ដោយសារគ្រោះមហន្តរាយធម្មជាតិ ។ ដើម្បីបញ្ចៀសផលប៉ះពាល់ពេលខាងមុខ ពួកគេបានរៀបចំទ្រព្យសម្បត្តិអាជីវកម្មផ្ទៃក្នុង ធនធានផលិតកម្ម ត្រៀមបម្រុងហិរញ្ញវត្ថុ និងទីតាំងអាជីវកម្ម ។

កត្តាមួយក្នុងចំណោមកត្តាទាំងអស់ ដែលមានឥទ្ធិពល ឬប្រសិទ្ធភាពលើការយល់ដឹងរបស់ក្រុមអាជីវករប្រភេទទីមួយ និងទីពីរ ដូចបានរៀបរាប់ខាងលើថាលទ្ធភាពទទួលបានព័ត៌មានពីអាកាសធាតុនូវមានកំរិត អាចជាប្រព័ន្ធប្រកាសអាសន្ន និងបច្ចេកវិទ្យាដែលអាចព្យាករណ៍អាកាសធាតុបាន។ ការរកឃើញនេះ បង្ហាញពីកម្មវិធីលើកកំពស់ការយល់ដឹង និងអន្តរាគមន៍លើការបន្សាំការប្រែប្រួលអាកាសធាតុក្នុងចំណោមអាជីវកម្មខ្នាតតូចនីមួយៗគឺនៅខ្វះចន្លោះ។

## អាជីវកម្មជួបប្រទះបញ្ហាប្រឈមទាំងខាងក្នុង និងខាងក្រៅក្នុងការឈានទៅភាពធន់ទៅនឹងអាកាសធាតុ

បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់អាជីវកម្មខ្នាតតូចជួបប្រទះ អាចនឹងគូសបង្ហាញតាមរយៈការសិក្សានេះ។ ដំបូងអាជីវកម្មខ្នាតតូចមិនមានភាពមិនច្បាស់លាស់ពី ហានិភ័យដែលអាចកើតឡើងដោយសារ កង្វះលទ្ធភាពទទួលបានព័ត៌មាន និង

មានកិច្ចសហប្រតិបត្តិការតិចតួច រវាងវិស័យសាធារណៈ និងវិស័យឯកជន ក្នុងករណីនេះ។ ទាំងនេះគឺគ្មានការត្រៀមខ្លួននៅក្នុងចំណោមអាជីវករម្នាក់ ក៏ដូចជារវាងស្ថាប័នសាធារណៈ និងឯកជន ដែលធ្វើឱ្យកើតមានកាន់តែធ្ងន់ធ្ងរនូវភាពងាយរងគ្រោះនៃអាជីវកម្មខ្នាត់តូច ចំពោះមុខសញ្ញាគ្រោះមហន្តរាយនៃការប្រែប្រួលអាកាធាតុ។ ការយល់ដឹងរបស់អាជីវកម្ម ពីហានិភ័យនាពេលអនាគត បានឆ្លុះបង្ហាញថា ភាគច្រើននៃពួកគេមានទំនោរពឹងផ្អែកលើចំណេះដឹងនៃបទពិសោធន៍កន្លងមក ជាជាងលើចក្ខុវិស័យមួយ ឬការណែនាំពីស្ថាប័នពាក់ព័ន្ធ។ ដូច្នេះការជួយសម្រួល និងផ្តល់លទ្ធភាពទទួលបានព័ត៌មានអាកាធាតុ និងបច្ចេកវិទ្យា ព្រមទាំងវិធីដោះស្រាយដែលអាចដំណើរការ និងអាចអនុវត្តបានសម្រាប់អាជីវកម្ម និងទីតាំងមួយចំនួនដែលត្រូវការ គឺពិតជាមានសារៈខាន់បំផុត។

បញ្ហាប្រឈមមួយផ្សេងទៀត បានបង្ហាញពីលក្ខណៈនៃអាជីវកម្មខ្នាតតូច ខ្លួនឯងផ្ទាល់ (ទំហំតូច និងសមត្ថភាពហិរញ្ញវត្ថុខ្សោយ) ដែលបានដាក់របាំង ដើម្បីក្លាយជាភាពធន់នឹងអាកាសធាតុ។ ភាពខ្សត់ខ្សោយ និងចំណេះដឹងនូវមានកំរិតពី គ្រោះមហន្តរាយបានធ្វើឲ្យពួកគេមិនអាចបង្កើតយុទ្ធសាស្ត្រសម្រាប់រយៈពេលវែង និងមានផ្ចត់គំនិតរឹងមាំមួយបាន។ ដូចនេះពួកគេភាគច្រើនប្រកាន់ភ្ជាប់នូវការឆ្លើយតបភ្លាមៗ និងឆ្លើយតបរយៈពេលខ្លី និងមិនបានឃើញការបន្សុំនឹងការប្រែប្រួលអាកាសធាតុថាជា ដូចជាការបង្កើតប្រាក់ចំណេញ សម្រាប់រយៈពេលវែងមួយ ជាលទ្ធផល ខ្សោយ ឬគ្មានការត្រៀមខ្លួនជាមុនទេ។

បញ្ហាប្រឈមទីបីគឺ កង្វះហេដ្ឋារចនាសម្ព័ន្ធដែលមានភាពបន្សុំ ទាំងរូបវ័ន្ត និងព័ត៌មាន។ នេះបានធ្វើឱ្យអាជីវកម្ម មានការបារម្ភពីគ្រោះហានិភ័យនាពេលអនាគត ក្រៅពីការអន្តរាគមន៍មួយចំនួន និងការឆ្លើយតបភ្លាមៗពីសំណាក់អាជ្ញាធរមូលដ្ឋាន។ កម្សោយហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយគ្រោះមហន្តរាយទៅលើអាជីវកម្ម។ ជាឧទាហរណ៍ អាជីវករបានរៀបរាបថា ផ្នែកកណ្តាលនៃក្រុងក្រចេះ ដែលជាកន្លែងប្រមូលផ្តុំអាជីវកម្ម ជាតំបន់ដីទាប នឹងជាកន្លែងទឹកហូរពីទន្លេលិចមុនគេ។ វាគឺជាតំបន់រងគ្រោះទឹកជំនន់ជាប្រចាំ ដែលជួនកាលភ្លៀងធំប៉ុន្មានម៉ោងក៏អាចធ្វើឱ្យជន់លិចដែរ។ លើសពីនេះប្រព័ន្ធលូត្រូវបានខូចខាត និងត្រូវបានបិទនូវផ្នែកណាមួយ ដែលនាំមានភាពងាយរងគ្រោះ។ នេះគឺជាបញ្ហាធ្ងន់ធ្ងរមួយ ដោយសារប្រព័ន្ធនេះមានសារៈសំខាន់សម្រាប់យុទ្ធសាស្ត្រកាត់បន្ថយទឹកជំនន់ទីក្រុង។

ម្យ៉ាងទៀត ដោយសារអវត្តមានហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា សម្រាប់ការផ្តល់ព័ត៌មានពីការប្រែប្រួលអាកាសធាតុ បានធ្វើឲ្យទន់ខ្សោយសមត្ថភាពអាជីវកម្ម ក្នុងការទប់ទល់នឹងគ្រោះមហន្តរាយផ្សេងៗ។ ការរាំងស្ទះនេះបាន ធ្វើឱ្យអាជីវកម្មមានប្រត្តិកម្ម ជាជាងចូលរួមយ៉ាងសកម្មជាមួយនឹងវិធានការដែលមានប្រសិទ្ធភាព និងជឿជាក់បាន ក្នុងកំឡុងពេលមានវិបត្តិម្តងៗ។ ភាពមិនអាចរកបាននៃហេដ្ឋារចនាសម្ព័ន្ធព័ត៌មាន ក៏បានបង្អាក់ប្រសិទ្ធភាពព័ត៌មាននៅថ្នាក់មូលដ្ឋាន ដែលត្រូវចែករំលែករវាងបណ្តាញអាជីវកម្ម និងព័ត៌មានផ្តល់មកវិញពីអាជីវកម្មទៅស្ថាប័នពាក់ព័ន្ធ។ ដោយសារកង្វះខាតនៃឧបករណ៍ព័ត៌មាន អាជីវកម្ម បានជួបប្រទះការលំបាកមួយចំនួនក្នុងការទទួលបានចំណេះថ្មីៗអំពីលក្ខខណ្ឌអាកាសធាតុផ្សេងៗ

ខណៈអាជ្ញាធរពាក់ព័ន្ធ បានរកឃើញថាវាពិបាកប្រមូលទិន្នន័យ និងរៀបចំគោលនយោបាយជាយុទ្ធសាស្ត្រ និងការអន្តរាគមន៍។ សរុបមកអាជីវកម្ម បានអនុវត្តយុទ្ធសាស្ត្របន្សាំមួយចំនួនរួចមកហើយ ប៉ុន្តែទាំងនេះវាមានលក្ខណៈបណ្តោះអាសន្ន និងអាស្រ័យលើគ្រោះមហន្តរាយ ដែលបានផ្តល់នូវព័ត៌មាន និងបណ្តាញគាំទ្រនៅមានដែនកំណត់ ។

អាជីវករភាគច្រើនរាយការណ៍ថា ពួកគេខ្វះការគាំទ្រពីខាងក្រៅ ដែលជាការចាំបាច់ ពីដៃគូអាជីវកម្មរបស់ពួកគេ សហគ្រាស និងអាជ្ញាធរដែលពាក់ព័ន្ធ។ ក្នុងចំណោមពួកគេគ្មាននរណាម្នាក់បាន លើកឡើងពីលទ្ធភាពទទួលបានឥណទាន ជំនួយ និងការធានារ៉ាប់រងសម្រាប់អាជីវកម្មរបស់ពួកគេទេ គឺមានតែការរៀបចំដោយខ្លួនឯងផ្ទាល់។

មានតែភ្នាក់ងារខាងក្រៅ ដែលធ្វើអន្តរាគមន៍កំឡុងពេល និងបន្ទាប់ពីគ្រោះមហន្តរាយនីមួយៗគឺ មានតែអាជ្ញាធរមូលដ្ឋាន ដែលពួកគាត់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានអនុញ្ញាតឱ្យអាជីវកម្មខ្នាតតូចរៀបចំសម្រាប់ និងធ្វើឱ្យប្រសើរឡើងវិញបន្ទាប់ពីគ្រោះទឹកជំនន់តាមរយៈការបូមទឹកជំនន់ចេញពីកណ្តាលផ្សារ និងតំបន់ដែលជន់លិច និងបានស្ថាបនាផ្លូវថ្មីៗ និងទំនប់ទឹកថ្មីៗក្នុងតំបន់ជុំវិញ។ ទោះជាយ៉ាងណាក៏ដោយ ការអន្តរាគមន៍នេះគឺ មិនទូលំទូលាយ និងមិនត្រូវបានបញ្ចូលក្នុងផែនការរបស់ស្ថាប័នឡើយ។ ការអនុវត្តរបៀបនេះ នៅពេលណាមួយ នឹងបណ្តាលឱ្យការអន្តរាគមន៍មិនស្ថិតស្ថេរ និងមិនសម្របសម្រួលឡើយ។ ជាឧទាហរណ៍មួយនៃការខ្វះយន្តការសម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋគឺមានភាពពិបាក ដើម្បីជ្រើសរើសទីកន្លែង ដែលផ្លាស់ទីមានសុវត្ថិភាពសម្រាប់អាជីវកម្មបន្ទាប់ពីផ្សារកណ្តាលបានជន់លិច។

## ការប្រើប្រាស់សម្រាប់គោលនយោបាយ

- កម្មវិធីលើកកម្ពស់ការយល់ដឹង និងការអន្តរាគមន៍លើការបន្សាំការប្រែប្រួលអាកាសធាតុក្នុងចំណោមអាជីវកម្មខ្នាតតូចនៅមានភាពខ្វះចន្លោះ។
- ការខំប្រឹងកាន់តែខ្លាំង និងដ៏ប្រសើរជាតម្រូវការ ដើម្បីធ្វើឱ្យអាជីវកម្មខ្នាតតូចទទួលយកការបន្សាំការប្រែប្រួលអាកាសធាតុ ដូចជាការផ្តល់នូវប្រាក់ចំណេញមួយ និងគោរពតាមការឆ្លើយតបរយៈពេលវែង។
- នេះតម្រូវឱ្យស្ថាបនាកម្មនៃអន្តរាគមន៍ និងការសម្របសម្រួលដ៏ប្រសើរ ក្នុងចំណោមតួអង្គរដ្ឋ ជាមួយនឹងវិស័យឯកជន។ ការទាញយកកម្មវិធី ដែលមានស្រាប់របស់អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ដែលកំពុងធ្វើការលើរឿងនេះ នឹងកើនឡើងទាំងការរួមបញ្ចូលគ្នា និងប្រសិទ្ធភាព។

## SOURCE

This policy brief has been prepared by Dr. Chanrith Ngin, The University of Auckland, New Zealand, and is based on the following material:

Chhom, C., Ngin, C. & Neef, A. (2019). Impacts of Climate Change on Small Businesses in Kratie Town, Kratie Province, Cambodia. APN Research Report.

Edited by Professor Andreas Neef, The University of Auckland, New Zealand



**About this publication:** This policy brief has been developed for the APN project "Climate Change Adaptation in Post-Disaster Recovery Processes: Flood-Affected Communities in Cambodia and Fiji" (CAF2017-RR05-CMY-Neef) under APN's Climate Adaptation Framework. For full details of this project, including news and events, project activities, publications and presentations, please visit the project website at http://www.climatechangeplus.net.

April 2019